# វិធីរបស់អារក្សសាតាំង ដើម្បីបំផ្លាញជំនឿរបស់គ្រីស្ទបរិស័ទ

តើមានអ្វីកើតឡើងនៅពេលដែលមនុស្សឮ ហើយទទួលជឿដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ? សូមអាន កិច្ចការ ២៦:១៦-១៨ :

**១៦ ចូរក្រោកឈរឡើង ដ្បិតខ្ញុំបានលេចមកឲ្យអ្នកឃើញ ដើម្បីនឹងតាំងអ្នក ឲ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់ ពីអស់ទាំងការដែលអ្នកបានឃើញហើយ ព្រមទាំងការដែលខ្ញុំនឹងលេចមក ឲ្យអ្នកឃើញទៅមុខទៀត ១៧ ខ្ញុំបានញែកអ្នកចេញពីបណ្តាជន និងពីពួកសាសន៍ដទៃ ដើម្បីនឹងចាត់អ្នកឲ្យទៅឯគេវិញ ១៨ ប្រយោជន៍នឹងបំភ្លឺ ភ្នែកគេ ឲ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរដក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ**

ខទាំងនេះបង្ហាញថា មានព្រះគុនអស្ចារ្យដ៏ធំខ្លះ ដែលកើតឡើង នៅពេលដែលមនុស្សទទួល ជឿដំណឹងល្អរបស់ទ្រង់ :

1. អ្នកដែលពីមុនខ្វះភ្នែកខាងឯវិញ្ញាណ ហើយស្គាល់សេចក្តីពិតមិនបាននោះ ត្រូវបានព្រះ បើកភ្នែករបស់គេ ឲ្យមើលឃើញសេចក្តីពិតបានទៅវិញ

2. អ្នកដែលពីមុននៅជាប់ក្នុងសេចក្តីងងឹត ព្រះអង្គបានទាញពួកគេឲ្យចេញពីសេចក្តីងងឹត ហើយចូលក្នុងពន្លឺរបស់ព្រះទៅវិញ

3. អ្នកដែលពីមុននៅក្រោមអំណាចរបស់អារក្សសាតាំង បានរួចខ្លួនចេញពីការសង្កត់សង្កិន របស់វា ចូលក្នុងនគររបស់ព្រះ ដែលមានព្រះពរវិញ។

4. អ្នកដែលពីមុននៅជាប់មានទោសធ្ងន់ ត្រូវបានទទួលការលើកលែងទោស ហើយបានទទួលភាពជាកូនព្រះ និងមានមរដករបស់ព្រះគ្រីស្ទ

តើអ្នកគិតថា អារក្សសាតាំងមានការប្រតិកម្មអ្វីខ្លះ នៅពេលដែលនរណាម្នាក់ជឿលើព្រះយេស៊ូវ? តើអ្នកគិតថា វានឹងមានការប្រតិកម្មអ្វី នៅឯភូមិណាដែលមានក្រុមជំនុំព្រះយេស៊ូវថ្មីដោះឡើង នៅទីនោះ?

- នៅពេលដែលយើងអានព្រះគម្ពីរ កិច្ចការ យើងឃើញយ៉ាងច្បាស់អំពីការ ប្រតិកម្មរបស់វា។ អ្នកដឹកនាំសាសនាចាប់ផ្តើមប្រឆាំងនិងអ្នកជឿ ហើយនាំឲ្យប្រជាជនបៀតបៀនដល់គេផង។ នេះហើយជាវិធីមួយរបស់អារក្សសាតាំង។
- នៅពេលដែលយើងអាន សំបុត្ររបស់ពួកសាវក យើងឃើញលោកទាំងនោះ លើកទឹកចិត្ត ហើយបង្រៀនអ្នកជឿ។ មួយទៀត យើងឃើញពាក្យព្រមាន និងពាក្យស្តីបន្ទោសដែរ។ ហេតុអ្វីបានជាពួកសាវកប្រើពាក្យព្រមាន និងពាក្យស្តីបន្ទោសនោះ? ពីព្រោះលោកទាំងអស់ នោះដឹងថា អារក្សសាតាំង កំពង់តែរកស៊ីបំផ្លាញជំនឿរបស់គេ ដូច្នេះលោកសាវកខំថែទាំ ជំនឿរបស់កូនចៀមនៃព្រះទៅវិញ។

តើអារក្សសាតាំងតែងតែប្រើវិធីឯណាទៀត ដើម្បីបំផ្លាញជំនឿរបស់គ្រីស្ទបរិស័ទ? មានវិធីពីរទៀតរបស់វា គឺ:

1. អារក្សសាតាំងប្រើគ្រូក្លែងក្លាយ ដែលផ្លាស់ផ្តូរឥតន័យដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ សូមអាន កាឡាទី ១:៦-៩ :

   **៦ ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែចេញពីព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាមកក្នុងព្រះគុណ នៃព្រះគ្រីស្ទ ជាឆាប់ម៉្លេះ និងទៅតាមដំណឹងល្អផ្សេងទៀតនោះ ៧ ដែលមិនមែនជាដំណឹងល្អ១ទៀតទេ គឺមានមនុស្សខ្លះបំភាន់អ្នករាល់គ្នាវិញ ហើយចង់បង្ខូចដំណឹងល្អព្រះគ្រីស្ទផង ៨ ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ៩ ឯសេចក្តីដែលខ្ញុំទើប នឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ១០ ដ្បិតតើខ្ញុំរក បញ្ចុះបញ្ចូលអ្នកណា តើជាមនុស្ស ឬព្រះ ឬចង់បំពេញចិត្តមនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបំរើរបស់ព្រះគ្រីស្ទទេ។**

   - ឧទាហរណ៍ គ្រូខ្លះបង្រៀនថា អ្នកជឿលើព្រះយេស៊ូវដើរផ្លូវពីរក៏បានដែរ ពីព្រោះគេអនុញ្ញាតអោយអ្នកជឿដើរក្នុងផ្លូវបាប។ ពាក្យ ជឿ របស់ពួកគេគ្មានន័យថា កែប្រែទេ គេបង្រៀនថា យើងជឿដោយគ្មានការកែប្រែចិត្តក៏បានដែរ។

2. អារក្សសាតាំងប្រើសេចក្តីល្បួងដែរ។ វាខំប្រឹងល្បួងអ្នកជឿលើព្រះឲ្យត្រឡប់ទៅផ្លូវបាបវិញ កុំឲ្យគេដើរក្នុងជីវិតថ្មីរបស់ព្រះទេ។ តើហេតុអ្វីបានជាវាខំប្រឹងនាំយើងឲ្យប្រព្រឹត្តបាបដូច្នេះ? ពីព្រោះវាដឹងថា អស់អ្នកណាដែលមិនព្រមកែប្រែចិត្ត ដើម្បីដើរតាមព្រះយេស៊ូវនោះ អ្នកនោះ

នៅតែក្រោមអំណាចរបស់វាដដែលទេ ហើយអ្នកនោះ មិនទាន់ជាកូនរបស់ព្រះផង។ សូមអាន
ខគម្ពីរនេះ :
ត្រូវប្រព្រឹត្ត ដូច្នោះ ដោយដឹងពេលវេលាថា ដល់ម៉ោងនឹងភ្ញាក់ពីដេកហើយ ដ្បិតឥឡូវនេះ សេចក្តីសង្គ្រោះ
បានមកជិតបង្កើយ ជាជាងកាលយើងទើបនឹងជឿនោះ ១២ យប់យូរណាស់ហើយ ថ្ងៃក៏ជិតរះ ដូច្នេះ យើង
ត្រូវដោះចោលអស់ទាំងការរបស់សេចក្តីងងឹតចេញ ហើយពាក់គ្រឿងសឹករបស់ពន្លឺវិញ ១៣ ត្រូវឲ្យយើង
ដើរតាម ដែលគួរគប្បី ដូចជាដើរនៅពេលថ្ងៃ មិនមែនដោយស៊ីផឹក លេងល្បែង ឬមានស្រីញី ឬដោយ
ឈ្លោះប្រកែក និងឈ្នានីស នោះឡើយ ១៤ គឺត្រូវប្រដាប់ខ្លួន ដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ ហើយកុំ
ឲ្យផ្គត់ផ្គង់ ដើម្បីនឹងបំពេញសេចក្តីប៉ងប្រាថ្នា ខាងឯសាច់ឈាមឡើយ។ (រ៉ូម ១៣:១២-១៤)

ខ្ញុំបានផ្ញើសំបុត្រផ្ញើមកប្រាប់អ្នករាល់គ្នាថា កុំឲ្យភប់ប្រសព្វនឹងមនុស្សកំផិតឡើយ ១០ តែពាក្យនោះមិន
សំដៅ ចំពោះមនុស្សកំផិតរបស់ផងលោកីយ៍នេះ ឬមនុស្សលោភ មនុស្សប្លន់កំហែង ឬមនុស្សថ្វាយបង្គំរូប
ព្រះនោះទេ ដ្បិតបើដូច្នោះ នោះត្រូវតែចេញឲ្យផុតពីលោកីយ៍នេះទៅ ១១ គឺខ្ញុំបានសរសេរមក អ្នករាល់គ្នា
ដោយន័យយ៉ាងនេះថា បើមានអ្នកណានៅក្នុងពួកជំនុំ ជាមនុស្សកំផិត ឬលោភ ឬថ្វាយបង្គំរូបព្រះ ឬជេរ
ប្រមាថ ជាអ្នកប្រមឹក ឬប្លន់កំហែង នោះមិនត្រូវឲ្យភប់ប្រសព្វនឹងគេឡើយ ក៏មិនត្រូវទាំងបរិភោគជាមួយ
នឹងគេផង ១២ ដ្បិតតើត្រូវការអ្វីឲ្យខ្ញុំជំនុំជំរះដល់មនុស្សខាងក្រៅ តើអ្នករាល់គ្នាមិនជំនុំជំរះមនុស្សក្នុងពួក
ជំនុំទេឬអី ១៣ ឯចំណែកពួកអ្នកខាង ក្រៅ នោះព្រះនឹងជំនុំជំរះគេ ហើយត្រូវឲ្យអ្នករាល់គ្នាបណ្តេញ
មនុស្សអាក្រក់នោះ ពីពួកអ្នករាល់គ្នាចេញ។ (កូរិនថូស ទី១ ៥:៩-១៣)
៩ តើមិនដឹងថា ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរដកទេឬអី កុំឲ្យច្រឡំឡើយ ដ្បិតពួក
មនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកអ្នកសំរេចកិច្ចដោយខ្លួនឯង ពួកលេងកូនជឹង
១០ ពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះដៀល និងពួកប្លន់កំហែង នោះមិនដែលបានគ្រងនគរ
ព្រះទុកជាមរដកឡើយ ១១ ឯពួកអ្នករាល់គ្នា ខ្លះ ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះដែរ តែបានលាងស្អាត
ហើយ ក៏បានញែកជាបរិសុទ្ធ ហើយរាប់ជាសុចរិតផង ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវ និងព្រះ
វិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា។ (កូរិនថូស ទី១ ៦:៩-១១)

រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តី កំផិត សហាយស្មន់ ស្មោកគ្រោក
អាសអាភាស ២០ ថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់
បែក បក្សពួក ២១ ច្រណែន កាប់សំឡាប់ ប្រមឹក ស៊ីផឹកជ្រុល និងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តី
ទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្ត

> ដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ ២២ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តី
> ស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ២៣ ស្លូតបូត ហើយដឹងខ្នាត គ្មាន
> ក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ ២៤ ហើយអស់អ្នកដែលជា របស់ផងព្រះគ្រីស្ទ នោះបាន
> ឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល និងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង ២៥ បើសិនជាយើងរស់
> ដោយនូវព្រះវិញ្ញាណ នោះត្រូវដើរដោយព្រះវិញ្ញាណដែរ ២៦ កុំឲ្យយើងរាល់គ្នារកកេរ្តិ៍ឈ្មោះ ដែលឥត
> ប្រយោជន៍ ទាំងចាក់រុក ហើយឈ្នានីសគ្នាទៅវិញទៅមកឡើយ។ (កាឡាទី ៥:១៩-២៦)

យោងតាមព្រះគម្ពីរនេះ យើងឃើញច្បាស់ថា មានអំពើបាបខ្លះ ដែលអារក្សសាតាំងប្រើ ដោយភាពខ្ជះខ្ជែង ដើម្បីឲ្យអ្នកជឿវង្វេងចេញពីព្រះ។ អស់ទាំងអ្នកដែលមិនព្រមកែប្រែតាមជីវិតថ្មីក្នុងព្រះយេស៊ូវ គ្មានឈ្មោះជាកូនរបស់ព្រះទេ ពីព្រោះអ្នកទាំងនោះគ្មានចិត្តចុះចូលនូវចំពោះព្រះទេ មិនចង់ទទួលព្រះយេស៊ូវជាម្ចាស់នៃជីវិតខ្លួនទេ ជាអ្នកមិនជឿដដែល។ សូមមើលខគម្ពីរនៅលើម្តង ទៀត ហើយសូមមានការយកចិត្តទុកដាក់ទៅលើ ការប្រព្រឹត្តអាក្រក់ដែលអ្នកជឿលើព្រះត្រូវតែ ដោះចោលចេញពីជីវិតនោះ។

នេះហើយជាការបោកបញ្ឆោតរបស់អារក្សសាតាំង គឺនាំឲ្យមនុស្សស្រឡាញ់បាបជាជាងព្រះ នាំឲ្យចង់បានអំពើបាបជាជាងសេចក្តីសង្គ្រោះ ហើយនាំឲ្យគេយកវាជាម្ចាស់របស់ខ្លួន មិនមែន ព្រះដែលស្រឡាញ់ពួកគេវិញ។ សូមអាន អេភេសូរ ៥:១-១២

១ ដូច្នេះ ចូរត្រាប់តាមព្រះ ដូចជាកូនស្ងួនភ្ងា ២ ហើយដើរក្នុងសេចក្តី ស្រឡាញ់ ដូចជាព្រះគ្រីស្ទបានស្រឡាញ់
យើង ព្រមទាំងប្រគល់ព្រះអង្គទ្រង់ជំនួសយើងផង ទុកជាដង្វាយ ហើយជាយញ្ញបូជា សំរាប់ជាក្លិនឈ្ងុយថ្វាយដល់
ព្រះ។ ៣ ឯសេចក្តី កំផិត សេចក្តីស្មោកគ្រោកគ្រប់យ៉ាង និងសេចក្តីលោភ នោះមិនត្រូវទាំងឲ្យឮឈ្មោះក្នុងពួកអ្នក
រាល់គ្នាផង ដូចជាគួរគប្បីក្នុងពួកបរិសុទ្ធ ៤ ព្រមទាំងរឿងគួរខ្មាស ពាក្យសំដីចំកួត និងពាក្យកំប្លែង ដែលសេចក្តី
ទាំងនោះមិនគួរគប្បីដែរ ស៊ូពោលតែពាក្យសំរាប់អរព្រះគុណវិញ ៥ ដ្បិតអ្នករាល់គ្នាដឹង ថា គ្មានមនុស្សកំផិត ឬ
ស្មោកគ្រោក ឬលោភ គឺជាមនុស្សថ្វាយបង្គំរូបព្រះ ដែលនឹងគ្រងមរដកក្នុងនគរនៃព្រះគ្រីស្ទ ហើយនៃព្រះផងបាន
ឡើយ ៦ កុំឲ្យអ្នកណាបញ្ឆោត អ្នករាល់គ្នា ដោយពាក្យសំដីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្តីទាំង
នោះ បានជាសេចក្តីក្រោធរបស់ព្រះ បានមកលើមនុស្សរឹងចចេស ៧ ដូច្នេះ កុំឲ្យមានចំណែកជា១នឹងគេឡើយ
៨ ដ្បិតកាលពីដើមអ្នករាល់គ្នាក៏ងងឹតដែរ តែឥឡូវនេះវិញ បានភ្លឺក្នុងព្រះអម្ចាស់ ដូច្នេះ ចូរដើរដូចជាមនុស្សភ្លឺចុះ
៩ ដ្បិតផលផ្លែនៃពន្លឺ នោះមាននៅក្នុងគ្រប់ទាំងកិរិយាល្អ សេចក្តីសុចរិត និងសេចក្តីពិត ១០ ចូរលមើលឲ្យដឹងសេច
ក្តីអ្វី ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចុះ ១១ កុំឲ្យប្រកបក្នុងការឥតផលប្រយោជន៍របស់សេចក្តីងងឹតឡើយ

**ស៊ូបន្ទោសវិញ ១២ ដ្បិតការទាំងប៉ុន្មានដែលគេប្រព្រឹត្តដោយសំងាត់ នោះបើគ្រាន់តែនិយាយពីការទាំងនោះ ក៏គួរខ្មាសទៅហើយ**

យោងតាមព្រះគម្ពីរច្បាស់ទាំងអស់នេះ យើងទាំងអស់គ្នាត្រូវមានចិត្តពឹងទៅលើព្រះយេស៊ូវ ជាព្រះអង្គសង្រ្គោះរបស់ខ្លួន ដើម្បីមានការប្រព្រឹត្តដែលបញ្ជាក់ពីការកែប្រែចិត្តរបស់ខ្លួន។ អ្នកជឿត្រូវមានការអាណិតអាសូរដល់អ្នកដែលជំពប់ដួល ហើយជួយអ្នកទាំងនោះឲ្យឈរឡើងវិញ ក្នុងព្រះគុណនៃព្រះ។ អស់អ្នកដែលមិនព្រមដើរតាមព្រះ ប៉ុន្តែមានចិត្តបន្តក្នុងផ្លូវបាប អ្នកនោះ ត្រូវដាច់ចេញពីក្រុមជំនុំ រហូតដល់គាត់បន្ទាបខ្លួន ហើយសំរេចចិត្តដើរតាមព្រះអង្គទ្រង់។ បើគ្មានដូចជាមានក្នុងមេរៀននេះទេ យើងមិនស្មោះត្រង់ចំពោះព្រះ ឬដំណឹងល្អរបស់ទ្រង់ឡើយ។

សូមឲ្យបងប្អូនទាំងឡាយណា ដែលជឿដំនឹងល្អរបស់ព្រះក្នុងសេចក្តីពិត ឲ្យចេះការពារដំណឹងល្អនោះដោយការប្រព្រឹត្តតាមវាក្នុងកំឡាំងដែលមកពីព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ។ កុំចាញ់ការបោក បញ្ឆោតរបស់អារក្សសាតាំងឡើយ!